# ព្រះរាជក្រម

នស/រកម/០៨២២/ ០១០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ក្រុមប្រឹក្សាធម្មនុញ្ញ
អគ្គលេខាធិការដ្ឋាន
ចូល
លេខ: ១៧៣
ថ្ងៃ: ...ទី ២៣ ខែ... ឆ្នាំ២០២២
ម៉ោង: ១១:៣០

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២ នាសម័យប្រជុំរដ្ឋសភា លើកទី៧ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី៥ ខែសីហា ឆ្នាំ២០២២ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់

# ស្តីពី

# ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ច្បាប់នេះមានគោលបំណងគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ សម្រាប់ជាចំណូលថវិកាជាតិ ប្រកបដោយប្រសិទ្ធភាព សក្តិសិទ្ធិភាព តម្លាភាព គណនេយ្យភាព និងសង្គតិភាព ដោយកំណត់ក្របខ័ណ្ឌច្បាប់ ស្ថាប័នជាគោលយន្តការ វិធាន និងនីតិវិធីនៃការគ្រប់គ្រងការប្រមូលចំណូលមិនមែនសារពើពន្ធគ្រប់ប្រភេទ សំដៅចូលរួមចំណែកបម្រើឧត្តមប្រយោជន៍នៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២ .-**

ច្បាប់នេះជាច្បាប់គោលមានវិសាលភាពអនុវត្តចំពោះចំណូលមិនមែនសារពើពន្ធគ្រប់ប្រភេទ ដែលអនុវត្តដោយក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ ក្រុមហ៊ុនចម្រុះដែលរដ្ឋមានភាគកម្មសាធារណៈជាចំនួនភាគតិច អង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត និងភាគីឯកជនពាក់ព័ន្ធ ដែលស្ថិតក្រោមអធិបតេយ្យភាព និង/ឬយុត្តាធិការនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣ .-**

បច្ចេកសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ មាននិយមន័យកំណត់ក្នុងសទ្ទានុក្រម ដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ។

## ជំពូកទី២

## ចំណូលមិនមែនសារពើពន្ធ

### ផ្នែកទី១

### ប្រភេទចំណូលមិនមែនសារពើពន្ធ

**មាត្រា៤ .-**

ចំណូលមិនមែនសារពើពន្ធ ត្រូវបានបែងចែក ដូចខាងក្រោម៖

១- ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ។

២- ចំណូលពីសហគ្រាសសាធារណៈ ភាគកម្មសាធារណៈ និងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត។

៣- ចំណូលពីសេវាសាធារណៈ។

៤- ចំណូលពីការពិន័យនិងការដាក់ទណ្ឌកម្ម។

៥- ចំណូលមិនមែនសារពើពន្ធដទៃទៀត ដូចមានកំណត់ក្នុងមាត្រា ៣៣ នៃច្បាប់នេះ។

ចំណូលមិនមែនសារពើពន្ធ ដែលជាប្រភេទចំណូលថ្មី ក្រៅពីប្រភេទចំណូលមិនមែនសារពើពន្ធខាងលើ ត្រូវកំណត់នៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ។

## ផ្នែកទី២
## ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ

**មាត្រា៥ .-**

ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ មានជាអាទិ៍៖

១- ចំណូលពីការលក់ឬការដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។

២- ចំណូលពីការជួលទ្រព្យសម្បត្តិរដ្ឋ។

៣- ចំណូលពីសម្បទានសេវាសាធារណៈ។

៤- ចំណូលពីធនធានធម្មជាតិ។

៥- ចំណូលផ្សេងៗទៀតដែលមានចែងក្នុងលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ។

**មាត្រា៦ .-**

ចំណូលពីការលក់ឬការដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ជាចំណូលដែលទទួលបានមកពីការលក់ ឬការដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋជាចលនទ្រព្យនិងអចលនទ្រព្យ។

ការលក់ ឬការដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ត្រូវអនុវត្តតាមវិធាននិងនីតិវិធីដូចមានកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**មាត្រា៧ .-**

ចំណូលពីការលក់ ឬការដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋជាចលនទ្រព្យ មានជាអាទិ៍៖

- ការលក់ឯកសារ ឬលតាបត្រ ឬលិខិតបោះពុម្ពផ្សេងៗ
- ផលបានពីការលក់ទ្រព្យសម្បត្តិកម្មេចកម្មី សត្វពាហនៈ
- ការលក់ផលិតផលកសិកម្ម
- ផលបានពីការជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋជាចលនទ្រព្យ
- ការលក់ចលនទ្រព្យ ដែលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដទៃទៀត។

**មាត្រា៨ .-**

ចំណូលពីការលក់ឬការដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ជាអចលនទ្រព្យ មានជាអាទិ៍៖

- ចំណូលពីការលក់ដី ឬប្រាក់លម្អៀងពីការដោះដូរដី និង/ឬសំណង់អគារ
- ផលបានពីការជម្រះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋជាអចលនទ្រព្យដទៃទៀត។

**មាត្រា៩ .-**

ចំណូលពីការជួលទ្រព្យសម្បត្តិរដ្ឋ ជាចំណូលដែលទទួលបានមកពីថ្លៃជួល ភាគចំណែករបស់រដ្ឋ និងការបែងចែកផលចំណេញ ដូចមានចែងក្នុងកិច្ចសន្យាឬកិច្ចព្រមព្រៀងនៃការជួលទ្រព្យសម្បត្តិរដ្ឋជាចលនទ្រព្យនិង/ឬអចលនទ្រព្យ មានជាអាទិ៍៖

- ការជួលដីនិងអគារ
- ការជួលអគារឬសំណង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ
- ការជួលសម្ភារៈបរិក្ខារ មធ្យោបាយដឹកជញ្ជូន និងគ្រឿងចក្រ
- ការជួលទ្រព្យសម្បត្តិរដ្ឋជាចលនទ្រព្យនិងអចលនទ្រព្យដទៃទៀត។

ការជួលទ្រព្យសម្បត្តិរដ្ឋ ត្រូវអនុវត្តតាមវិធាននិងនីតិវិធី ដូចមានកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា១០ .-**

ចំណូលពីការជួលដីនិងអគារ ជាចំណូលដែលទទួលបានមកពីការជួលដីទំនេររបស់រដ្ឋឬការជួលដីមានអគារដែលជាការជួលដីនិងអគារទាំងមូលរបស់រដ្ឋ។

**មាត្រា១១ .-**

ចំណូលពីការជួលអគារឬសំណង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ជាចំណូលដែលទទួលបានមកពីការជួលផ្នែកនៃអគារឬសំណង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ មានជាអាទិ៍ ការជួលការិយាល័យ ការជួលអាហារដ្ឋាន ការជួលកន្លែងផ្សព្វផ្សាយ ការជួលកន្លែងលក់ដូរ ឬការជួលសំណង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ។

**មាត្រា១២ .-**

ចំណូលពីការជួលសម្ភារៈបរិក្ខារ មធ្យោបាយដឹកជញ្ជូន និងគ្រឿងចក្រ ជាចំណូលដែលទទួលបានមកពីការជួលសម្ភារៈ មធ្យោបាយដឹកជញ្ជូន និងគ្រឿងចក្ររបស់រដ្ឋ មានជាអាទិ៍ បរិក្ខារបច្ចេកទេសនិងឧស្សាហកម្ម យានយន្តម៉ាស៊ីនស្ទូច ត្រាក់ទ័រ។

**មាត្រា១៣ .-**

ចំណូលពីសម្បទានសេវាសាធារណៈ ចែកចេញជាចំណូលពីគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន និងចំណូលពីសម្បទានគ្រប់គ្រងសេវាសាធារណៈ ដែលមានដូចខាងក្រោម៖

ក. **ចំណូលពីគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន** ជាចំណូលដែលទទួលបានមកពីគម្រោងវិនិយោគ ដូចមានកំណត់ក្នុងលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធពាក់ព័ន្ធនឹងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និង/ឬការផ្គត់ផ្គង់សេវាសាធារណៈ មានជាអាទិ៍៖

- ហេដ្ឋារចនាសម្ព័ន្ធនិងសេវាសាធារណៈបម្រើដល់វិស័យដឹកជញ្ជូននិងវិស័យភស្តុភារកម្ម មានជាអាទិ៍ ផ្លូវថ្នល់ ស្ពាន ផ្លូវដែក អាកាសយានដ្ឋាន កំពង់ផែ ចំណតសាធារណៈ ព្រែកជីក
- ហេដ្ឋារចនាសម្ព័ន្ធប្រៃសណីយ៍និងទូរគមនាគមន៍ បច្ចេកវិទ្យាព័ត៌មាន និងបច្ចេកវិទ្យាឌីជីថល
- ការផលិត ការបញ្ជូន និងការចែកចាយថាមពលអគ្គិសនី បំពង់បង្ហូរប្រេងនិងឧស្ម័ន និងសេវាសាធារណៈផ្សេងទៀត ក្នុងវិស័យរ៉ែនិងថាមពល
- ហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យ ប្រព័ន្ធលូ ប្រព័ន្ធបង្ហូរទឹក ប្រព័ន្ធប្រមូលស្ដារប្រព្រឹត្តិកម្មទឹកកខ្វក់ ការគ្រប់គ្រងសំណល់ និងសេវាសាធារណៈផ្សេងទៀតបម្រើឱ្យកិច្ចគាំពារបរិស្ថាន
- ហេដ្ឋារចនាសម្ព័ន្ធនិងសេវាសាធារណៈពាក់ព័ន្ធនឹងវិស័យសុខាភិបាល វិស័យអប់រំ វិស័យការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ វិស័យទេសចរណ៍ វិស័យវប្បធម៌និងសិល្បៈ វិស័យកីឡា និងលំនៅឋានសង្គម
- ហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ មានជាអាទិ៍ តំបន់សេដ្ឋកិច្ចពិសេស សួនបណ្ដុំឧស្សាហកម្មធុនតូចនិងមធ្យម សួនបច្ចេកវិទ្យានិងនវានុវត្តន៍
- ហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធនឹងសេវាមន្ទីរពិសោធន៍ ការគាំទ្រការកែច្នៃ ការរក្សាផលិតផល និងការជំរុញពាណិជ្ជកម្ម
- ហេដ្ឋារចនាសម្ព័ន្ធនិងសេវាសាធារណៈពាក់ព័ន្ធនឹងវិស័យកសិកម្មនិងប្រព័ន្ធធារាសាស្ត្រ
- ហេដ្ឋារចនាសម្ព័ន្ធនិងសេវាសាធារណៈផ្សេងទៀតដែលច្បាប់ដោយឡែកអនុញ្ញាត។

វៀរលែងតែមានកំណត់នៅក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ចំណូលពីគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន មានរូបភាពជាភាគចំណែករបស់រដ្ឋដែលគិតជាភាគរយនៃចំណូលដុលតាមការព្រមព្រៀងរវាងភាគីរដ្ឋនិងភាគីឯកជន។

ការគ្រប់គ្រងគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន ត្រូវអនុវត្តតាមវិធាននិងនីតិវិធី ដូចមានកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

ខ.ចំណូលពីសម្បទានគ្រប់គ្រងសេវាសាធារណៈ ជាចំណូលទទួលបានមកពីការប្រគល់សិទ្ធិជូនបុគ្គលឯកជន ដើម្បីធ្វើអាជីវកម្មលើទ្រព្យសម្បត្តិរដ្ឋ ឬសេវាសាធារណៈដែលពុំមែនជាសេវាអធិបតេយ្យរបស់រដ្ឋ តាមរយៈលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ ក្នុងគោលដៅបម្រើសេវាសាធារណៈជូនដល់សាធារណជន ប្រកបដោយប្រសិទ្ធភាពនិងសក្តិសិទ្ធិភាព ដែលមានជាអាទិ៍ ផ្សារ កំពង់ចម្លង ចំណតយានជំនិះ ចំណតជលយាន មជ្ឈមណ្ឌលបែងចែកផលនេសាទ សត្តឃាតដ្ឋាន អនាម័យសត្វ ទីលានទុកដាក់សំរាមសំណល់រឹងទីប្រជុំជន ស្ថានីយផ្ទេរសំរាមសំណល់រឹងទីប្រជុំជន សេវាអនាម័យ ការរៀបចំសណ្តាប់ធ្នាប់សាធារណៈ វៀរលែងតែសេវាសាធារណៈដែលមានកំណត់ក្នុងចំណុច ក ខាងលើ។ ចំណូលនេះ ត្រូវបានកំណត់ក្នុងទម្រង់ជាការបែងចែកផល ដែលរដ្ឋទទួលបានចំណូលអាស្រ័យទៅតាមកំណើនអាជីវកម្មរបស់បុគ្គលឯកជន។

ការគ្រប់គ្រងសម្បទានគ្រប់គ្រងសេវាសាធារណៈ ត្រូវអនុវត្តតាមវិធាននិងនីតិវិធី ដូចមានកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**មាត្រា១៤ .-**

ចំណូលពីសម្បទានគ្រប់គ្រងសេវាសាធារណៈ ត្រូវបានបែងចែកជាប្រភេទចំណូល មានជាអាទិ៍ ៖

- ចំណូលពីចំណតយានជំនិះ ជាចំណូលដែលទទួលបានមកពីការផ្តល់សិទ្ធិរបស់រដ្ឋលើការធ្វើអាជីវកម្មចំណតយានជំនិះគ្រប់ប្រភេទ ដូចជា រថយន្ត ម៉ូតូ កង់ជាដើម ជូនដល់បុគ្គលឯកជន
- ចំណូលពីចំណតជលយាន ជាចំណូលដែលទទួលបានមកពីការផ្តល់សិទ្ធិរបស់រដ្ឋលើការធ្វើអាជីវកម្មទូក កាណូត កប៉ាល់ ការប្រើប្រាស់កំពង់ផែ ចំណតជើងទឹក ជូនដល់បុគ្គលឯកជន
- ចំណូលពីសត្តឃាតដ្ឋាន ជាចំណូលទទួលបានមកពីកន្លែងធ្វើអាជីវកម្មពិឃាដសត្វនៅតាមសត្តឃាតដ្ឋាន
- ចំណូលពីការជួលកន្លែងលក់ដូរក្នុងផ្សារ ជាចំណូលដែលទទួលបានមកពីការជួលតូប រាន ស្តង់ កន្លែងលក់ដូរក្នុងផ្សារដទៃទៀត
- ចំណូលពីកំពង់ចម្លង ជាចំណូលដែលទទួលបានមកពីការបម្រើសេវាកម្មចម្លងអ្នកធ្វើដំណើរ សត្វពាហនៈ សម្ភារៈ និងយានយន្តគ្រប់ប្រភេទ នៅតាមកំពង់ដ ដទទឹង ដបណ្តោយដែលរដ្ឋបានកំណត់
- ចំណូលពីមជ្ឈមណ្ឌលបែងចែកផលនេសាទ ជាចំណូលដែលទទួលបានមកពីអាជីវកម្មដែលធ្វើការប្រមូលផ្តុំ និងបែងចែកការប្រើប្រាស់ផលនេសាទដែលរដ្ឋបានកំណត់
- ចំណូលពីភាស៊ីផ្សារ ជាចំណូលដែលទទួលបានមកពីការប្រមូលពីអាជីវករលក់ដូរក្នុងនិងក្រៅផ្សារដែលរដ្ឋបានកំណត់
- ចំណូលពីអនាម័យសត្វ ជាចំណូលដែលទទួលបានមកពីការត្រួតពិនិត្យសុខភាពសត្វនៅសត្តឃាតដ្ឋាន ឬបានមកពីការត្រួតពិនិត្យអនាម័យសត្វតាមការដឹកជញ្ជូន នាំចេញ នាំចូល
- ចំណូលពីទីលានទុកដាក់សំរាម និងចំណូលពីស្ថានីយផ្ទេរសំរាមជាចំណូលដែលទទួលបានមកពីការផ្តល់កន្លែងទុកដាក់ កន្លែងផ្ទេរ និងការទាញយកធនធាន ឬប្រព្រឹត្តិកម្មសំរាម សំណល់រឹងទីប្រជុំជនសម្រាប់បុគ្គលដែលប្រើប្រាស់ទីតាំង
- ចំណូលពីសេវាអនាម័យ ជាចំណូលដែលទទួលបានមកពីកម្រៃសេវាប្រមូលសំរាមតាមលំនៅឋាន និងអាជីវកម្មដ្ឋានផ្សេងៗ
- ចំណូលពីសម្បទានដទៃទៀតរបស់រដ្ឋ ដែលពាក់ព័ន្ធនឹងសេវាសាធារណៈ។

**មាត្រា១៥ ._**

ចំណូលពីធនធានធម្មជាតិ ជាចំណូលដែលទទួលបានមកពីការចាត់ចែងលើធនធានធម្មជាតិ មានជាអាទិ៍ សម្បទានរ៉ែ ចំណូលពីប្រេងកាត សម្បទានដីសេដ្ឋកិច្ច ផលព្រៃឈើ អនុផលព្រៃឈើ ផលពីនេសាទ ធនធានកម្រ និងធនធានធម្មជាតិដទៃទៀត តាមរយៈលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ ក្នុងទម្រង់ជាកម្រៃស្នួយសារ ឬការបង់ថ្លៃឈ្នួល ឬបុព្វលាភ ឬភាគចំណែករបស់រដ្ឋ ឬការបែងចែកផល ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**មាត្រា១៦ ._**

ចំណូលពីធនធានធម្មជាតិ ត្រូវបានបែងចែកជាប្រភេទចំណូល មានជាអាទិ៍៖

- ផលពីព្រៃឈើ មានជាអាទិ៍ ចំណូលពីការលក់ឈើឈរ ស្នួយសារ បុព្វលាភ ផលព្រៃឈើ អនុផលព្រៃឈើ
- ចំណូលពីប្រេងកាត មានជាអាទិ៍ ចំណូលបានមកពីការធ្វើអាជីវកម្មប្រេងកាតដោយរដ្ឋ ថ្លៃឈ្នួលផ្ទៃក្រឡាប្លុកប្រេងកាត ចំណូលពីស្នួយសារប្រេងកាត ចំណូលពីចំណែកផលប្រេងកាតរបស់រដ្ឋ ប្រាក់រង្វាន់ចុះហត្ថលេខាលើកិច្ចព្រមព្រៀងប្រេងកាត
- ចំណូលពីសម្បទានរ៉ែ មានជាអាទិ៍ ចំណូលបានមកពីថ្លៃឈ្នួលផ្ទៃក្រឡាសម្រាប់ដំណាក់កាលស្វែងរុករករ៉ែនិងដំណាក់កាលធ្វើអាជីវកម្មធនធានរ៉ែ ចំណូលទទួលបានពីស្នួយសារផលិតផលរ៉ែ ភាគចំណែករបស់រដ្ឋពីការធ្វើអាជីវកម្មធនធានរ៉ែ
- ចំណូលពីសម្បទានដីសេដ្ឋកិច្ច ជាចំណូលបានមកពីកិច្ចសន្យានិងកិច្ចព្រមព្រៀងសម្បទានដីសេដ្ឋកិច្ច
- ផលពីនេសាទ ជាចំណូលបានមកពីការជួលឡូតិ៍នេសាទ
- ចំណូលពីធនធានកម្រ មានជាអាទិ៍ ចំណូលបានមកពីប្រេកង់វិទ្យុ
- ចំណូលបានមកពីការប្រើប្រាស់សេវាប្រព័ន្ធអេកូឡូស៊ី
- ចំណូលបានមកពីធនធានធម្មជាតិដទៃទៀត។

**មាត្រា១៧ ._**

វិធាននិងនីតិវិធីនៃការគ្រប់គ្រងចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ត្រូវកំណត់ដោយអនុក្រឹត្យ។

## ផ្នែកទី៣

## ចំណូលពីសហគ្រាសសាធារណៈ ភាគកម្មសាធារណៈ និងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត

**មាត្រា១៨ ._**

ចំណូលពីសហគ្រាសសាធារណៈ ភាគកម្មសាធារណៈ និងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត រួមមាន ចំណូលដែលទទួលបានមកពីការបង់៖

- [illegible]គលាភឬអតិរេកសាច់ប្រាក់
- [illegible]បើសនៃទុនទំនេរ
- ការ[illegible]សាច់ប្រាក់ និងសមមូលសាច់ប្រាក់ក្រោយពីសហគ្រាសនិងអង្គភាពត្រូវបានរំលាយ។

**មាត្រា១៩ .-**

ការបង់ភាគលាភឬអតិរេកសាច់ប្រាក់ និងភាគលើសនៃទុនទំនេរ ត្រូវអនុវត្តតាមបែបបទនិងនីតិវិធីដែលកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងសហគ្រាសសាធារណៈ ភាគកម្មសាធារណៈ និងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត។

**មាត្រា២០ .-**

ក្នុងករណីដែលច្បាប់ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបង្កើតសហគ្រាសសាធារណៈឬអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត ពុំបានចែងអំពីការកំណត់បែងចែកភាគលាភតាមអត្រាកំណត់គិតជាភាគរយនៃប្រាក់ចំណេញសុទ្ធឬអតិរេកទេនោះ និងវៀរលែងតែមានការសម្រេចដោយឡែករបស់រាជរដ្ឋាភិបាល សហគ្រាសសាធារណៈឬអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត ត្រូវមានកាតព្វកិច្ចបង់ភាគលាភឬអតិរេកសាច់ប្រាក់ ចូលថវិការដ្ឋយ៉ាងតិចចំនួន ១០% (ដប់ភាគរយ) នៃប្រាក់ចំណេញសុទ្ធឬអតិរេកសាច់ប្រាក់ បន្ទាប់ពីក្រុមប្រឹក្សាភិបាលឬគណៈគ្រប់គ្រងបានពិនិត្យនិងអនុម័តលើតុល្យការនិងគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**មាត្រា២១ .-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានសិទ្ធិសម្រេចក្នុងការកំណត់ឱ្យសហគ្រាសសាធារណៈនិងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត ធ្វើការបង់មួយចំណែក ឬទាំងអស់ នូវភាគលើសនៃទុនទំនេរ ចូលថវិកាជាតិ ក្នុងករណីពិនិត្យឃើញថា សហគ្រាសសាធារណៈឬអង្គភាពស្វ័យភាពហិរញ្ញវត្ថុណាដែលពុំមានតម្រូវការចាំបាច់សម្រាប់វិនិយោគ ឬអភិវឌ្ឍសហគ្រាសសាធារណៈឬអង្គភាពស្វ័យភាពហិរញ្ញវត្ថុរបស់ខ្លួន។

**មាត្រា២២ .-**

វៀរលែងតែមានបដិប្បញ្ញត្តិដែលចែងដោយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការរំលាយសហគ្រាសសាធារណៈ ក្រុមហ៊ុនចម្រុះដែលរដ្ឋមានភាគកម្មសាធារណៈជាចំនួនភាគតិចឬអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត សមមូលសាច់ប្រាក់ដែលជាចំណែករបស់ភាគីរដ្ឋ ត្រូវបង្វែរចូលគណនីទោលរតនាគារ។ រីឯទ្រព្យសកម្មដែលជាចលនទ្រព្យនិងអចលនទ្រព្យ ត្រូវបង្វិលចូលជាកម្មសិទ្ធិរបស់រដ្ឋវិញ ក្រោយពីបានធ្វើការជម្រះបញ្ជីតាមនីតិវិធីជាធរមាន និងស្របតាមលក្ខន្តិកៈរបស់សហគ្រាសឬរបស់ក្រុមហ៊ុន ឬការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀតនោះ។

**មាត្រា២៣ .-**

សហគ្រាសសាធារណៈ ក្រុមហ៊ុនចម្រុះដែលរដ្ឋមានភាគកម្មសាធារណៈជាចំនួនភាគតិច និងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត ដែលយឺតយ៉ាវឬខកខានក្នុងការបង់ចំណូលចូលថវិការដ្ឋ ដូចមានចែងក្នុងផ្នែកទី៣នៃជំពូកទី២នៃច្បាប់នេះ ត្រូវចាត់ទុកជាបំណុលមិនមែនសារពើពន្ធ ដូចមានកំណត់ក្នុងជំពូកទី៥នៃច្បាប់នេះ។

## ផ្នែកទី៤
## ចំណូលពីសេវាសាធារណៈ

**មាត្រា២៤ .-**

ចំណូលពីសេវាសាធារណៈ ជាចំណូលដែលប្រមូលបានមកពីការបង់កម្រៃនៃការប្រើប្រាស់សេវាសាធារណៈដោយរូបវន្តបុគ្គល ឬនីតិបុគ្គលសម្រាប់សេវាបង់ថ្លៃរបស់រដ្ឋ។ ការផ្តល់សេវាសាធារណៈនិងការប្រមូលចំណូលពីសេវាសាធារណៈ ត្រូវបានអនុវត្តដោយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងគោលដៅបម្រើផលប្រយោជន៍ទូទៅ។ កម្រៃសេវាសាធារណៈ ជាកម្មវត្ថុដែលត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងរដ្ឋមន្ត្រីក្រសួងឬប្រធានស្ថាប័នសាមី។

**មាត្រា២៥ .-**

សេវាសាធារណៈដែលផ្តល់ដោយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំជាកម្រងសេវាសាធារណៈ និងផ្សព្វផ្សាយជាសាធារណៈដោយមានរាយលម្អិតអំពីប្រភេទសេវា តម្លៃសេវា ឬតម្លៃអតិបរមានៃសេវា រយៈពេលអតិបរមា នៃការផ្តល់សេវា និងសុពលភាពនៃសេវាទៅតាមប្រភេទសេវាសាធារណៈនីមួយៗ។

**មាត្រា២៦ .-**

សេវាសាធារណៈ អាចត្រូវបានផ្តល់ដោយភាគីឯកជន តាមរយៈកិច្ចសន្យាដែលធ្វើឡើងរវាងភាគីឯកជននិងក្រសួង ស្ថាប័នឬរវាងភាគីឯកជននិងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២៧ .-**

វិធាននិងនីតិវិធីនៃការគ្រប់គ្រងនិងចាត់ចែងចំណូលពីសេវាសាធារណៈ ត្រូវកំណត់ដោយអនុក្រឹត្យ។

## ផ្នែកទី៥
## ចំណូលពីការពិន័យនិងការដាក់ទណ្ឌកម្ម

**មាត្រា២៨ .-**

វៀរលែងតែការពិន័យនិងការដាក់ទណ្ឌកម្មពាក់ព័ន្ធនឹងចំណូលសារពើពន្ធ ចំណូលពីការពិន័យនិងការដាក់ទណ្ឌកម្ម មានជាអាទិ៍ ចំណូលពីការផាកពិន័យ ចំណូលពីការផ្តន្ទាទោសពិន័យជាប្រាក់ ចំណូលពីការរឹបអូស ផលពីការពិន័យផ្សេងៗ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន សម្រាប់ជាគុណប្រយោជន៍ដល់ថវិកាជាតិ។

**មាត្រា២៩ .-**

ចំណូលពីការផាកពិន័យ ជាចំណូលមិនមែនសារពើពន្ធ ដែលប្រមូលបានមកពីការពិន័យអន្តរការណ៍ចំពោះការប្រព្រឹត្តល្មើសនឹងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ការពិន័យជាប្រាក់ចំពោះការមិនគោរពតាមលក្ខខណ្ឌដែលមានចែងក្នុងលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធនានា រួមទាំងការប្រាក់លើទឹកប្រាក់ផាកពិន័យ ដែលអនុវត្តដោយក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ច។

**មាត្រា៣០ .-**

ចំណូលពីការផ្តន្ទាទោសពិន័យជាប្រាក់ ជាចំណូលមិនមែនសារពើពន្ធដែលប្រមូលបានតាមរយៈសេចក្តីសម្រេចរបស់តុលាការមានសមត្ថកិច្ច ចំពោះការប្រព្រឹត្តល្មើសនឹងច្បាប់ និង/ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**មាត្រា៣១ .-**

ចំណូលពីការរឹបអូស មានជាអាទិ៍៖

- ចំណូលពីការរឹបអូសប្រាក់កក់ ជាចំណូលដែលទទួលបានមកពីការរឹបអូសប្រាក់កក់នៃការដេញថ្លៃ និងប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា
- ចំណូលពីការរឹបអូសទ្រព្យសម្បត្តិ ជាចំណូលដែលទទួលបានមកពីការរឹបអូសទ្រព្យសម្បត្តិជាហិរញ្ញវត្ថុពីបទល្មើសនិងពីការចាត់ចែងទ្រព្យសម្បត្តិរឹបអូសជាចលនទ្រព្យនិងអចលនទ្រព្យពីបទល្មើស មានជាអាទិ៍ បទល្មើសគ្រឿងញៀន បទល្មើសព្រៃឈើ បទល្មើសដទៃទៀត។

**មាត្រា៣២ .-**

វិធាននិងនីតិវិធីនៃការគ្រប់គ្រងចំណូលពីការពិន័យនិងការដាក់ទណ្ឌកម្ម ត្រូវកំណត់ដោយអនុក្រឹត្យ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

# ផ្នែកទី៦
# ចំណូលមិនមែនសារពើពន្ធដទៃទៀត

**មាត្រា៣៣ .-**

ចំណូលមិនមែនសារពើពន្ធដទៃទៀត ជាចំណូលដែលទទួលបានជាអាទិ៍មកពីៈ

១-ទ្រព្យនិទាយាទ។

២-ទ្រព្យគ្មានម្ចាស់គ្រប់គ្រង។

៣-ប្រទានកម្ម។

៤-អច្ច័យទាន។

៥-វិស័យសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

៦-វិស័យល្បែងពាណិជ្ជកម្ម។

៧-ផលហិរញ្ញវត្ថុ។

៨-ផលផ្សេងៗ និងផលពិសេសដទៃទៀត។

៩-មូលនិធិទៅតាមវិស័យពាក់ព័ន្ធ។

**មាត្រា៣៤ .-**

ចំណូលពីទ្រព្យនិទាយាទ ជាចំណូលទទួលបានមកពីការចាត់ចែងទ្រព្យដែលពុំមានសន្តតិជនដែលត្រូវក្លាយមកជាទ្រព្យសម្បត្តិរដ្ឋ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**មាត្រា៣៥ .-**

ចំណូលពីទ្រព្យគ្មានម្ចាស់គ្រប់គ្រង ជាចំណូលទទួលបានមកពីការចាត់ចែងទ្រព្យដែលក្លាយមកជាទ្រព្យសម្បត្តិរដ្ឋដោយហេតុផលទ្រព្យនោះពុំមានម្ចាស់គ្រប់គ្រង ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**មាត្រា៣៦ .-**

ចំណូលពីប្រទានកម្ម ជាចំណូលដែលទទួលបានមកក្រោមទម្រង់ជាអំណោយជាហិរញ្ញវត្ថុ និងចំណូលពីការចាត់ចែងទ្រព្យជាចលនទ្រព្យឬអចលនទ្រព្យ ដែលទទួលបានពីប្រទានកម្មសម្រាប់ជាគុណប្រយោជន៍ដល់ថវិកាជាតិ។

**មាត្រា៣៧ .-**

អច្ច័យទាន ជាចំណូលដែលទទួលបានមកក្រោមទម្រង់ជាអំណោយជាហិរញ្ញវត្ថុដែលទទួលតាមរយៈមតកសាសន៍ និងចំណូលពីការចាត់ចែងទ្រព្យជាចលនទ្រព្យឬអចលនទ្រព្យ ដែលទទួលបានតាមរយៈមតកសាសន៍ ដោយអនុលោម តាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន សម្រាប់ជាគុណប្រយោជន៍ដល់ថវិកាជាតិ។

**មាត្រា៣៨ .-**

ចំណូលពីវិស័យសេវាហិរញ្ញវត្ថុមិនមែនធនាគារ ជាចំណូលដែលទទួលបានជាអាទិ៍មកពី វិស័យធានារ៉ាប់រងនិងសោធនឯកជន វិស័យមូលបត្រ វិស័យសន្តិសុខសង្គម វិស័យបរធនបាលកិច្ច វិស័យគណនេយ្យនិងសវនកម្ម វិស័យអចលនវត្ថុ វិស័យបញ្ចាំនិងប្រាតិភោគដោយអនុប្បទាន ក្រៅពីចំណូលដែលមានកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**មាត្រា៣៩ .-**

ចំណូលពីវិស័យល្បែងពាណិជ្ជកម្ម ជាចំណូលដែលបានមកពីល្បែងកាស៊ីណូ ល្បែងភ្នាល់ ល្បែងផ្សងសំណាង និងល្បែងពាណិជ្ជកម្មដទៃទៀត ក្រៅពីចំណូលដែលមានកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**មាត្រា៤០ .-**

ផលហិរញ្ញវត្ថុ ជាចំណូលដែលបានមកពីការយកអតិរេកសាច់ប្រាក់បណ្តោះអាសន្នទៅវិនិយោគលើមូលបត្រអាចជួញដូរបាន អត្រាការប្រាក់លើបំណុល និងកម្រៃផ្សេងទៀតដែលបានមកពីប្រតិបត្តិការហិរញ្ញវត្ថុ។

**មាត្រា៤១ .-**

ផលផ្សេងៗនិងផលពិសេស ជាចំណូលដែលទទួលបានមកពីការបង់អតិរេកថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ ចំណូលពីការបង់អតិរេករបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពសាធារណៈប្រហាក់ប្រហែល ទឹកប្រាក់បង្វិលចូលថវិការដ្ឋ ដោយការបើកផ្តល់លើសសម្រាប់ការអនុវត្តគម្រោង និងផល ឬចំណូលផ្សេងៗទៀត ដែលត្រូវបានកំណត់ដោយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**មាត្រា៤២ .-**

មូលនិធិទៅតាមវិស័យពាក់ព័ន្ធ ជាចំណូលមិនមែនសារពើពន្ធដែលប្រមូលបានពីការបង់ប្រាក់ពីវិស័យឯកជន និងសាធារណៈ ផ្អែកតាមកាតព្វកិច្ច ឬតាមគោលការណ៍ស្ម័គ្រចិត្ត ដែលមានកំណត់ក្នុងលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ ឬក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**មាត្រា៤៣ .-**

វិធាននិងនីតិវិធីនៃការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធពីទ្រព្យនិទាយាទ ទ្រព្យគ្មានម្ចាស់ ប្រទានកម្ម អច្ច័យទាន វិស័យសេវាហិរញ្ញវត្ថុមិនមែនធនាគារ វិស័យល្បែងពាណិជ្ជកម្ម ផលហិរញ្ញវត្ថុ និងផលផ្សេងៗនិងផលពិសេស ត្រូវកំណត់ដោយអនុក្រឹត្យ។

វិធាននិងនីតិវិធីនៃការគ្រប់គ្រងនិងការប្រើប្រាស់មូលនិធិតាមវិស័យ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័នសាមី។

## ផ្នែកទី៧
## លិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ

**មាត្រា៤៤ .-**

រាល់ការបង្កើត ការកែប្រែ ឬការរំលាយលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ ឬការផ្ទេរមួយផ្នែក ឬទាំងស្រុងនូវសិទ្ធិនិងកាតព្វកិច្ច ដូចមានកំណត់ក្នុងលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ ត្រូវទទួលការពិនិត្យនិងឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ការបង្កើត ការកែប្រែ ឬការរំលាយលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ ឬការផ្ទេរមួយផ្នែក ឬទាំងស្រុងនូវសិទ្ធិនិងកាតព្វកិច្ច ដូចមានកំណត់ក្នុងលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ ក្នុងករណីមិនបានទទួលការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចាត់ទុកជាមោឃៈ។

លិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ ត្រូវតម្កល់ទុកនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចធ្វើប្រតិភូកម្មសិទ្ធិអំណាចក្នុងការចុះហត្ថលេខាលើលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធនានាទៅឱ្យតំណាងឬមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ដោយអនុលោមតាមវិធាននិងនីតិវិធីជាធរមាន។

**មាត្រា៤៥ .-**

លិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធពាក់ព័ន្ធនឹងការជួលទ្រព្យសម្បត្តិរដ្ឋ សម្បទានធនធានធម្មជាតិ និងសម្បទានសេវាសាធារណៈ ក្រោមរូបភាពជាគម្រោងវិនិយោគ គម្រោងសម្បទាន និងគម្រោងអភិវឌ្ឍន៍ អាចជាកម្មវត្ថុនៃការបង្កើតសិទ្ធិដល់អ្នកជួល ឬសម្បទានិក ឬវិនិយោគិន ឬអ្នកអភិវឌ្ឍ ក្នុងការផ្ទេរមួយផ្នែក ឬទាំងស្រុងនូវសិទ្ធិនិងកាតព្វកិច្ច ដូចមានកំណត់ក្នុងលិខិតគតិយុត្តនោះទៅឱ្យតតិយជន ក្នុងរយៈពេលមិនលើសពីរយៈពេលដែលមានកំណត់ក្នុងលិខិតគតិយុត្តទាំងនោះ បន្ទាប់ពីមានការពិនិត្យនិងឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងត្រូវបង់កម្រៃនៃការផ្ទេរសិទ្ធិលើលិខិតគតិយុត្ត ឬកម្រៃនៃការផ្ទេរគម្រោង ចូលថវិកាជាតិ។

វិធាននិងនីតិវិធីលម្អិត និងការកំណត់កម្រៃនៃការផ្ទេរមួយផ្នែកឬទាំងស្រុង នូវសិទ្ធិនិងកាតព្វកិច្ច ដូចមានកំណត់ក្នុងលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

**មាត្រា៤៦ .-**

ភាគីរដ្ឋ មានសិទ្ធិរំលាយលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធមុនពេលកំណត់ ក្នុងករណីណាមួយដូចខាងក្រោម៖

១-ខកខានក្នុងការបង់ចំណូលជូនរដ្ឋគ្រប់ចំនួនក្រោយឥណប្រតិទានយ៉ាងយូរបំផុត ១៨០ ថ្ងៃ ក្នុងករណីមិនមានប្រធានសក្តិកើតមានឡើង។

២-ប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ។

៣-តម្រូវការក្នុងការបម្រើប្រយោជន៍សាធារណៈ តាមការសម្រេចរបស់រាជរដ្ឋាភិបាល។

៤-រូបវន្តបុគ្គលឬនីតិបុគ្គល ត្រូវបានប្រកាសក្ស័យធនឬអសាធនភាព ដោយអនុលោមតាមច្បាប់ជាធរមាន។

លក្ខខណ្ឌដូចមានចែងក្នុងមាត្រានេះ ជាវិធានអប្បបរមាដែលភាគីអាចព្រមព្រៀងកំណត់នូវលក្ខខណ្ឌបន្ថែមក្នុងលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

## ជំពូកទី៣
## ស្ថាប័នមានសមត្ថកិច្ច
### ផ្នែកទី១
### ស្ថាប័នមានសមត្ថកិច្ចថ្នាក់ជាតិ

**មាត្រា៤៧ .-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បំពេញមុខងារជាសេនាធិការជូនរាជរដ្ឋាភិបាលលើរាល់ប្រតិបត្តិការគ្រប់គ្រង តាមដាន ត្រួតពិនិត្យ វាយតម្លៃការអនុវត្តការប្រមូលចំណូលមិនមែនសារពើពន្ធ រួមបញ្ចូលទាំងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងចាត់វិធានការតឹងទារបំណុលមិនមែនសារពើពន្ធទាំងអស់របស់ព្រះរាជាណាចក្រកម្ពុជា។ ក្នុងការបំពេញមុខងារនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានតួនាទីនិងភារកិច្ច ដូចតទៅ៖

- រៀបចំក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រង ការតាមដាន និងការត្រួតពិនិត្យការប្រមូលចំណូលមិនមែនសារពើពន្ធ
- បង្កើតនិងគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- ផ្សព្វផ្សាយ ណែនាំ និងជំរុញការអនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងចំណូលមិនមែនសារពើពន្ធ

- ជំរុញការកៀរគរ ការកត់ត្រា និងការត្រួតពិនិត្យចំណូលមិនមែនសារពើពន្ធគ្រប់មុខសញ្ញាដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ
- ដឹកនាំការតឹងទារនិងការដោះស្រាយបំណុលមិនមែនសារពើពន្ធ
- គ្រប់គ្រង តាមដាន និងត្រួតពិនិត្យការអនុវត្តការប្រមូលចំណូលមិនមែនសារពើពន្ធ របស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ
- ត្រួតពិនិត្យនិងវាយតម្លៃភាពត្រឹមត្រូវនៃរបាយការណ៍ស្តីពីការអនុវត្តការប្រមូលចំណូលមិនមែនសារពើពន្ធប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ អនុលោមតាមបទប្បញ្ញត្តិគតិយុត្តជាធរមាន
- រៀបចំរបាយការណ៍ស្តីពីការអនុវត្តការប្រមូលចំណូលមិនមែនសារពើពន្ធប្រចាំឆ្នាំ និងលើកសំណើដំណោះស្រាយលើបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងគណនេយ្យភាពនិងបូរណភាពនៃការរៀបចំរបាយការណ៍ស្តីពីការអនុវត្តការប្រមូលចំណូលមិនមែនសារពើពន្ធ ជូននាយករដ្ឋមន្ត្រីពិនិត្យនិងសម្រេច
- ពិនិត្យនិងសម្រេចលើការកែសម្រួលចំណូលមិនមែនសារពើពន្ធ ឬលើកសំណើជូននាយករដ្ឋមន្ត្រី ពិនិត្យនិងសម្រេច
- រៀបចំសំណើវិធានការលើកទឹកចិត្តឬសំណើវិធានការរឹតត្បិត ពាក់ព័ន្ធនឹងការអនុវត្តការប្រមូលចំណូលមិនមែនសារពើពន្ធ ជូននាយករដ្ឋមន្ត្រីពិនិត្យនិងសម្រេច
- ត្រួតពិនិត្យនិងធ្វើអធិការកិច្ចហិរញ្ញវត្ថុលើការប្រមូលចំណូលមិនមែនសារពើពន្ធ របស់ក្រសួង ស្ថាប័ននិងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ
- ដឹកនាំដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការប្រមូលចំណូលមិនមែនសារពើពន្ធ ដោយរាយការណ៍ជូននាយករដ្ឋមន្ត្រី។

**មាត្រា៤៨ .-**

ក្រសួង ស្ថាប័នដែលប្រមូលចំណូលមិនមែនសារពើពន្ធ បំពេញភារកិច្ចក្នុងការគ្រប់គ្រងនិងប្រមូលចំណូលមិនមែនសារពើពន្ធ ដូចតទៅ៖

- រៀបចំគម្រោងចំណូលថវិកាប្រចាំឆ្នាំ សម្រាប់ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ
- ដឹកនាំនិងគ្រប់គ្រងការប្រមូលចំណូលមិនមែនសារពើពន្ធគ្រប់ប្រភេទ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន
- អនុវត្តការប្រមូលចំណូលមិនមែនសារពើពន្ធគ្រប់ប្រភេទ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន
- កៀរគរ កត់ត្រាចំណូលមិនមែនសារពើពន្ធគ្រប់ប្រភេទដែលប្រមូលបាន
- ចាត់វិធានការលើបំណុលមិនមែនសារពើពន្ធ ដែលត្រូវតឹងទារ
- រៀបចំរបាយការណ៍ស្តីពីការអនុវត្តការប្រមូលចំណូលមិនមែនសារពើពន្ធប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ
- ដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការប្រមូលចំណូលមិនមែនសារពើពន្ធស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន និងស្នើសុំវិធានការដោះស្រាយពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងករណីពុំអាចដោះស្រាយបាន។

**មាត្រា៤៩ .-**

ក្រសួង ស្ថាប័នដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវបង្កើតគណៈកម្មការ អនុគណៈកម្មការ ឬក្រុមការងារតាមការចាំបាច់ ដើម្បីបំពេញមុខងារជាសេនាធិការ ក្នុងការគ្រប់គ្រងការប្រមូលចំណូលមិនមែនសារពើពន្ធឱ្យក្រសួង ស្ថាប័ននីមួយ ដែលប្រមូលចំណូលមិនមែនសារពើពន្ធនីមួយៗ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការ អនុគណៈកម្មការ ឬក្រុមការងារនេះ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

## ផ្នែកទី២
## ស្ថាប័នមានសមត្ថកិច្ចថ្នាក់ក្រោមជាតិ

**មាត្រា៥០ .-**

រដ្ឋបាលថ្នាក់ក្រោមជាតិ បំពេញមុខងារគ្រប់គ្រងនិងប្រមូលចំណូលមិនមែនសារពើពន្ធ នៅថ្នាក់ក្រោមជាតិដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួន អនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។ ក្នុងការបំពេញមុខងារនេះ រដ្ឋបាលថ្នាក់ក្រោមជាតិ មានតួនាទីនិងភារកិច្ចដូចតទៅ៖

- រៀបចំគម្រោងចំណូលថវិកាប្រចាំឆ្នាំសម្រាប់ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ
- ដឹកនាំនិងគ្រប់គ្រងការអនុវត្តការប្រមូលចំណូលមិនមែនសារពើពន្ធ ដោយរដ្ឋបាលថ្នាក់ក្រោមជាតិនិងមន្ទីរជំនាញនៃរាជធានី ខេត្ត
- ជំរុញការកៀគរនិងការកត់ត្រាទន្ទឹងគ្រប់មុខសញ្ញាចំណូលមិនមែនសារពើពន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនិងមន្ទីរជំនាញនៃរាជធានី ខេត្ត
- ចូលរួមដឹកនាំតឹងទារបំណុលមិនមែនសារពើពន្ធ នៅរាជធានី ខេត្ត
- រៀបចំនិងបូកសរុបរបាយការណ៍ស្តីពីការអនុវត្តការប្រមូលចំណូលមិនមែនសារពើពន្ធប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ របស់រដ្ឋបាលថ្នាក់ក្រោមជាតិនិងមន្ទីរជំនាញនៃរាជធានី ខេត្ត
- ពិនិត្យនិងសម្រេចលើរបាយការណ៍ស្តីពីការអនុវត្តការប្រមូលចំណូលមិនមែនសារពើពន្ធប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនិងមន្ទីរជំនាញនៃរាជធានី ខេត្ត ដើម្បីបញ្ជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការប្រមូលចំណូលមិនមែនសារពើពន្ធស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន និងស្នើសុំវិធានការដោះស្រាយពីក្រសួង ស្ថាប័នពាក់ព័ន្ធ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងករណីពុំអាចដោះស្រាយបាន។

មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ជាតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បំពេញមុខងារជាសេនាធិការជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៥១ .-**

ក្នុងករណីចាំបាច់ រដ្ឋបាលថ្នាក់ក្រោមជាតិ អាចបង្កើតគណៈកម្មការ ឬក្រុមការងារ ជាសេនាធិការ ដើម្បីពង្រឹងនិងបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងការប្រមូលចំណូលមិនមែនសារពើពន្ធ និងការតឹងទារបំណុលមិនមែនសារពើពន្ធ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការឬក្រុមការងារនេះ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

## ផ្នែកទី៣
## កិច្ចសហការអន្តរស្ថាប័ន

**មាត្រា៥២ .-**

ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចខាងក្រោម៖

- ផ្ញើឯកសារ ព័ត៌មាន និងទិន្នន័យទាំងឡាយពាក់ព័ន្ធនឹងការអនុវត្តចំណូលមិនមែនសារពើពន្ធ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- រៀបចំផែនការយុទ្ធសាស្ត្រនានាពាក់ព័ន្ធនឹងចំណូលមិនមែនសារពើពន្ធ
- គ្រោង កៀរគរ ប្រមូល បង់ និងបែងចែកចំណូលមិនមែនសារពើពន្ធ
- តឹងទារបំណុលមិនមែនសារពើពន្ធ
- ត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តការប្រមូលចំណូល
- ពិនិត្យលទ្ធភាពស្វែងរកប្រភពចំណូលមិនមែនសារពើពន្ធថ្មី
- សើរើនិងកំណត់តម្លៃនៃគ្រប់ប្រភេទចំណូលមិនមែនសារពើពន្ធក្នុងករណីចាំបាច់ ស្របទៅតាមស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ច ទីផ្សារ និងសង្គមនៃព្រះរាជាណាចក្រកម្ពុជា។

វិធាននិងនីតិវិធីនៃការសើរើនិងការកំណត់តម្លៃតាមប្រភេទចំណូលមិនមែនសារពើពន្ធ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

# ជំពូកទី៤

# ការប្រមូលចំណូលមិនមែនសារពើពន្ធ

## ផ្នែកទី១

## ការរៀបចំគម្រោងចំណូលមិនមែនសារពើពន្ធ

**មាត្រា៥៣ .-**

ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវរៀបចំគម្រោងចំណូលមិនមែនសារពើពន្ធនៃសាមីក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ទៅតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាចំណូលថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយអនុលោមតាមវិធាននិងនីតិវិធីហិរញ្ញវត្ថុជាធរមាន។

**មាត្រា៥៤ .-**

វិធាននិងនីតិវិធីនៃការរៀបចំគម្រោងចំណូលមិនមែនសារពើពន្ធរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវកំណត់ដោយអនុក្រឹត្យ។

## ផ្នែកទី២

## ការអនុវត្តការប្រមូលចំណូលមិនមែនសារពើពន្ធ

**មាត្រា៥៥ .-**

ចំណូលមិនមែនសារពើពន្ធត្រូវបានប្រមូល ដើម្បីជាគុណប្រយោជន៍ដល់ថវិកាថ្នាក់ជាតិនិងថវិកាថ្នាក់ក្រោមជាតិ។

ការបែងចែកចំណូលមិនមែនសារពើពន្ធ ដើម្បីជាគុណប្រយោជន៍ដល់ថវិកាថ្នាក់ជាតិនិងថវិកាថ្នាក់ក្រោមជាតិ ត្រូវអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**មាត្រា៥៦ .-**

ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវអនុវត្តការប្រមូលចំណូលមិនមែនសារពើពន្ធ ដែលមានកំណត់ជាអាទិ៍ ក្នុងលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ ប្រកាសអន្តរក្រសួងពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈនិងការពិន័យជាប្រាក់ សេចក្តីសម្រេចស្ថាពររបស់ស្ថាប័នតុលាការ ឬលិខិតបទដ្ឋានគតិយុត្តដទៃទៀត ដោយត្រូវធ្វើការកត់ត្រា តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការប្រមូលចំណូល ដោយអនុលោមតាមវិធាននិងនីតិវិធី ដែលកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**មាត្រា៥៧ .-**

ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវបង់ចំណូលដែលប្រមូលបានចូលថវិកាជាតិ ទៅតាមវិធាននិងនីតិវិធីហិរញ្ញវត្ថុជាធរមាន ដោយមិនអនុញ្ញាតឱ្យដកចំណូលនេះ ទៅកាត់កងដោយត្រង់ជាមួយចំណាយ ឬរក្សាទុកសាច់ប្រាក់ ឬមូលប្បទានបត្រនៅក្នុងបេឡាជួទេយ្យករចំណូល លើសពីចំនួនដែលបានអនុញ្ញាតដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬនាយករដ្ឋមន្ត្រី និង/ឬដែលបានកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមានឡើយ។

**មាត្រា៥៨ .-**

ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវបង់ចំណូលមិនមែនសារពើពន្ធដែលប្រមូល ឬទទួលបាន ចូលថវិកាជាតិដោយគោរពតាមគោលការណ៍ ដូចខាងក្រោមៈ

- បង់ចូលគណនីទោលរបស់រតនាគារឬធនាគារដៃគូ
- បង់តាមរយៈរជ្ជទេយ្យករចំណូលឬភ្នាក់ងារប្រមូលចំណូល។

ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវរៀបចំសលាកបត្របង់ចំណូលថវិកា ដែលជាសក្ខីបត្រមូលដ្ឋាននៃការបង់ចំណូលរបស់ខ្លួនសម្រាប់គណនេយ្យករសាធារណៈ ដោយអនុលោមតាមវិធាននិងនីតិវិធី ដែលកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន និង/ឬដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៥៩ .-**

វិធាននិងនីតិវិធីនៃការប្រមូលចំណូលនិងការបង់ចំណូលមិនមែនសារពើពន្ធ ត្រូវកំណត់ដោយអនុក្រឹត្យ។

## ផ្នែកទី៣
## ការកត់ត្រា ការតាមដាន និងការធ្វើរបាយការណ៍

**មាត្រា៦០ .-**

ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវរៀបចំបូកសរុបរបាយការណ៍ស្ដីពីការអនុវត្តការប្រមូលចំណូលមិនមែនសារពើពន្ធ នៅគ្រប់អង្គភាពក្រោមឱវាទរបស់សាមីក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រមូលចំណូលមិនមែនសារពើពន្ធ ដោយអនុលោមតាមវិធាននិងនីតិវិធីដែលមានចែងក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**មាត្រា៦១ .-**

ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវធ្វើការកត់ត្រាតាមដានស្ដីពីការអនុវត្តការប្រមូលចំណូល និងធ្វើរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ស្ដីពីស្ថានភាពនៃការអនុវត្តការប្រមូលចំណូល ផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យបានទៀងទាត់ ដោយអនុលោមតាមកាលបរិច្ឆេទ និងនីតិវិធីដែលមានកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវទទួលខុសត្រូវលើការទុកដាក់ឯកសារលិខិតយុត្តិការ និងកាន់កាប់បញ្ជិកាគណនេយ្យនូវរាល់ប្រតិបត្តិការប្រមូលចំណូលមិនមែនសារពើពន្ធ ដោយអនុលោមតាមវិធាននិងនីតិវិធីហិរញ្ញវត្ថុជាធរមាន។

វិធាននិងនីតិវិធីនៃការកត់ត្រា ការតាមដាន និងការធ្វើរបាយការណ៍ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៦២ .-**

នៅរៀងរាល់ដំណាច់ឆ្នាំ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវធ្វើការបូកសរុប និងផ្ទៀងផ្ទាត់លទ្ធផលនៃការអនុវត្តការប្រមូលចំណូលប្រចាំឆ្នាំរបស់ខ្លួន ព្រមទាំងធ្វើរបាយការណ៍វិភាគលទ្ធផលនៃការអនុវត្តការប្រមូលចំណូលប្រចាំឆ្នាំនោះ ដោយអនុលោមតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន។

វិធាននិងនីតិវិធីនៃការធ្វើរបាយការណ៍វិភាគលទ្ធផលនៃការអនុវត្តការប្រមូលចំណូលប្រចាំឆ្នាំ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៦៣ .-**

របាយការណ៍វិភាគលទ្ធផលនៃការអនុវត្តការប្រមូលចំណូលប្រចាំឆ្នាំ ត្រូវធ្វើជាមូលដ្ឋាននៃកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងនៃឆ្នាំនីមួយៗ។

## ផ្នែកទី៤
## ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ

**មាត្រា៦៤ .-**

ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធទាំងក្នុងនិងក្រៅប្រទេសដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រមូលចំណូលមិនមែនសារពើពន្ធ ជាកម្មវត្ថុនៃការធ្វើទំនើបកម្មតាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីពង្រឹងយន្តការប្រមូល កត់ត្រា និងតាមដានចំណូលនិងបំណុលមិនមែនសារពើពន្ធប្រកបដោយប្រសិទ្ធភាព សក្តិសិទ្ធិភាព និងគណនេយ្យភាព។

**មាត្រា៦៥ .-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺជាស្ថាប័ននិម្មាបនករ ក្នុងការបង្កើត ការគ្រប់គ្រប់គ្រង និងការដឹកនាំអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ។

**មាត្រា៦៦ .-**

ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវចូលរួមអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ឱ្យបានពេញលេញគ្រប់ជ្រុងជ្រោយ ស្របទៅតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវរៀបចំបង្កើតលេខអត្តសញ្ញាណចំណូលមិនមែនសារពើពន្ធគ្រប់ប្រភេទដោយលម្អិតតាមមុខចំណូលនីមួយៗ តាមការណែនាំ ការពិនិត្យ និងការសម្រេចអំពីអនុលោមភាព ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៦៧ .-**

រាល់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលបង្កើតឡើងដោយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ពាក់ព័ន្ធនឹងការប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវមានការចូលរួមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធានាអំពីការធ្វើសន្ទានកម្មទិន្នន័យ ជាមួយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងការផ្លាស់ប្តូរទិន្នន័យតាមរយៈថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា។

**មាត្រា៦៨ .-**

វិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

## ជំពូកទី៥
## បំណុលមិនមែនសារពើពន្ធ

**មាត្រា៦៩ .-**

បំណុលមិនមែនសារពើពន្ធ ជាចំនួនទឹកប្រាក់ នៃចំណូលមិនមែនសារពើពន្ធ ដែលបុគ្គលជាប់កាតព្វកិច្ចត្រូវបង់ខកខានក្នុងការបំពេញកាតព្វកិច្ចបង់ចំណូល ក្នុងរយៈពេលនិងលក្ខខណ្ឌដែលបានកំណត់ក្នុងលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ ឬបង្គាន់ដៃបង់ប្រាក់ពិន័យ ឬសេចក្ដីសម្រេចរបស់តុលាការមានសមត្ថកិច្ច ឬច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

សមាសភាគនៃបំណុលមិនមែនសារពើពន្ធ មានជាអាទិ៍ ចំនួនទឹកប្រាក់ដែលបុគ្គលជាប់កាតព្វកិច្ចត្រូវបង់ ខកខានក្នុងការបំពេញកាតព្វកិច្ចបង់ចំណូល ការប្រាក់ ប្រាក់ពិន័យ។

**មាត្រា៧០ .-**

ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវត្រួតពិនិត្យតាមដានជាប្រចាំ លើកាតព្វកិច្ចបង់ចំណូលមិនមែនសារពើពន្ធគ្រប់ប្រភេទ ដែលមានកំណត់ក្នុងលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ ។

ក្នុងករណីដែលបុគ្គលជាប់កាតព្វកិច្ចត្រូវបង់មិនបានអនុវត្តកាតព្វកិច្ចបង់ចំណូលរបស់ខ្លួននៅឥណប្រតិទានដែលមានចែងក្នុងលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ ព្រមទាំងច្បាប់និងលិខិតបទដ្ឋានគតិយុត្តដទៃទៀត ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវចាត់ទុកជាបំណុលមិនមែនសារពើពន្ធ និងត្រូវចាត់វិធានការលើបំណុលមិនមែនសារពើពន្ធ។

**មាត្រា៧១ .-**

ក្នុងករណីដែលបំណុលមិនមែនសារពើពន្ធ មិនអាចប្រមូលបានដោយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រមូលចំណូលមិនមែនសារពើពន្ធ បំណុលនោះត្រូវអនុវត្តវិធានការតឹងទារ តាមរយៈយន្តការក្រុមការងារអន្តរក្រសួងតឹងទារបំណុលមិនមែនសារពើពន្ធដែលដឹកនាំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៧២ .-**

បំណុលមិនមែនសារពើពន្ធ អាចជាកម្មវត្ថុនៃការជម្រះបញ្ជី ក្នុងករណីដូចខាងក្រោម៖

- កូនបំណុលជានីតិបុគ្គលដែលបានចុះបញ្ជីពាណិជ្ជកម្ម ត្រូវបានប្រកាសក្ស័យធន ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន
- កូនបំណុលត្រូវបានពិនិត្យនិងវាយតម្លៃអំពីអសាធនភាព ដោយក្រុមការងារអន្តរក្រសួងតឹងទារបំណុលមិនមែនសារពើពន្ធ
- កូនបំណុលបាត់ខ្លួន ឬអវត្តមាន ឬទទួលមរណភាពដោយគ្មានសិទ្ធិវន្តឬសន្តតិជន ដោយមានការបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច

- កូនបំណុលបានទូទាត់សងនូវបំណុលដែលជំពាក់គ្រប់ចំនួន និងចប់សព្វគ្រប់
- បំណុលដែលបាត់សាវតារនិងត្រូវបានវាយតម្លៃដោយក្រុមការងារអន្តរក្រសួងតឹងទារបំណុលមិនមែនសារពើពន្ធ
- បំណុលដែលត្រូវបានកំណត់ជាកម្មវត្ថុនៃការជម្រះបញ្ជីដោយលិខិតបទដ្ឋានគតិយុត្តជាធរមាន ឬដោយការសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៧៣ .-**

ការជម្រះបញ្ជីបំណុលមិនមែនសារពើពន្ធ ពុំមានអានុភាពគតិយុត្តធ្វើឱ្យផ្ដាច់សិទ្ធិរបស់រដ្ឋ ក្នុងការតឹងទារបំណុលមិនមែនសារពើពន្ធឡើយ ក្នុងករណីពិនិត្យឃើញថា៖

- កូនបំណុលដែលបានបញ្ជាក់អសាធនភាព មានសាធនភាពឡើងវិញ ឬ
- កូនបំណុលដែលបានបាត់ខ្លួន ឬអវត្តមាន បានបង្ហាញខ្លួន ឬមានវត្តមានវិញ ឬ
- កូនបំណុលដែលបានបញ្ជាក់ថាគ្មានសិទ្ធិវន្ត ឬគ្មានសន្តតិជន ត្រូវបានរកឃើញថាមានសិទ្ធិវន្តឬមានសន្តតិជនវិញ។

**មាត្រា៧៤ .-**

វិធាននិងនីតិវិធីនៃការតឹងទារ និងការជម្រះបញ្ជីនៃបំណុលមិនមែនសារពើពន្ធ ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៦
## ការដោះស្រាយវិវាទ

**មាត្រា៧៥ .-**

វៀរលែងតែមានកំណត់នៅក្នុងច្បាប់ឬលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធដទៃទៀត ក្នុងករណីមិនពេញចិត្តទៅនឹងការកំណត់តម្លៃ និង/ឬកិច្ចប្រតិបត្តិការនៃការប្រមូលចំណូលមិនមែនសារពើពន្ធដែលខុសទិសដៅ ឬផ្ទុយនឹងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាននោះ បុគ្គលដែលទទួលសេវាសាធារណៈ និងបុគ្គលដែលជាភាគីនៃលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ មានសិទ្ធិប្ដឹងតវ៉ាដោយត្រង់ទៅប្រធានស្ថាប័ននៃក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ឬតាមរយៈយន្តការដែលក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិបានបង្កើតសម្រាប់ទទួលពាក្យបណ្ដឹង និងដោះស្រាយវិវាទពាក់ព័ន្ធនឹងការប្រមូលចំណូលមិនមែនសារពើពន្ធ ឬប្ដឹងតវ៉ាទៅក្រសួង ស្ថាប័ន មានសមត្ថកិច្ចពាក់ព័ន្ធ។

**មាត្រា៧៦ .-**

ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រមូលចំណូលមិនមែនសារពើពន្ធ ដោយមានការចូលរួមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចបង្កើតក្រុមការងារឬគណៈកម្មការអន្តរក្រសួង ស្ថាប័ន ដើម្បីរៀបចំយន្តការដោះស្រាយវិវាទពាក់ព័ន្ធនឹងការកំណត់តម្លៃ និង/ឬកិច្ចប្រតិបត្តិការនៃការប្រមូលចំណូលមិនមែនសារពើពន្ធ។

**មាត្រា៧៧ .-**

វិធាននិងនីតិវិធីនៃការទទួល ការពិនិត្យ និងការដោះស្រាយវិវាទ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត ក្រសួង។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី៧

## អធិការកិច្ចនិងសវនកម្ម

**មាត្រា៧៨ .-**

ការអនុវត្តការប្រមូលចំណូលនិងការតឹងទារបំណុលមិនមែនសារពើពន្ធ ព្រមទាំងការលើកទឹកចិត្តនៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវទទួលរងអធិការកិច្ចហិរញ្ញវត្ថុដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង/ឬអធិការកិច្ច និង/ឬសវនកម្មដោយក្រសួង ស្ថាប័នមានសមត្ថកិច្ច ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៧៩ .-**

ក្នុងករណីសង្ស័យណាមួយ ដើម្បីត្រួតពិនិត្យតាមដានលើការអនុវត្តការប្រមូលចំណូលមិនមែនសារពើពន្ធ ការតឹងទារបំណុលមិនមែនសារពើពន្ធ ព្រមទាំងការជម្រះបញ្ជីបំណុលមិនមែនសារពើពន្ធនៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រមូលចំណូលមិនមែនសារពើពន្ធ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចាត់វិធានការណាមួយ ដូចខាងក្រោម៖

- ស្នើសាមីក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ឱ្យធ្វើសវនកម្មផ្ទៃក្នុង ឬអធិការកិច្ចដោយឡែក
- ធ្វើអធិការកិច្ចហិរញ្ញវត្ថុលើសាមីក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រមូលចំណូលមិនមែនសារពើពន្ធ
- ស្នើក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភានិងអធិការកិច្ច ធ្វើអធិការកិច្ចលើក្រសួង ស្ថាប័ននិងរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រមូលចំណូលមិនមែនសារពើពន្ធ។

# ជំពូកទី៨

## ការត្រួតពិនិត្យនិងការវាយតម្លៃ

**មាត្រា៨០ .-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចាត់វិធានការត្រួតពិនិត្យនិងវាយតម្លៃជាប្រចាំ លើការប្រមូលចំណូលនិងការតឹងទារបំណុលមិនមែនសារពើពន្ធនៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រមូលចំណូលមិនមែនសារពើពន្ធ។

**មាត្រា៨១ .-**

ត្រូវបានបង្កើតគណៈកម្មាធិការអន្តរក្រសួង ស្ថាប័នមួយ ដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីត្រួតពិនិត្យ តាមដាន និងវាយតម្លៃលើការប្រមូលនិងការគៀរគរចំណូលមិនមែនសារពើពន្ធរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រមូលចំណូលមិនមែនសារពើពន្ធ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការនេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

# ជំពូកទី៩
# ការលើកទឹកចិត្តនិងការដាក់ទណ្ឌកម្ម
## ផ្នែកទី១
## ការលើកទឹកចិត្ត

**មាត្រា៨២ .-**

ត្រូវបានផ្តល់ការលើកទឹកចិត្តចំពោះក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ និងអ្នករាជការសាធារណៈ ដែលមានស្នាដៃក្នុងការប្រមូលចំណូលនិងការតឹងទារបំណុលមិនមែនសារពើពន្ធប្រកបដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងសក្តិសិទ្ធិភាព។

**មាត្រា៨៣ .-**

ការពិនិត្យ ការវាយតម្លៃ និងការផ្តល់ការលើកទឹកចិត្ត ត្រូវផ្អែកលើលក្ខណៈវិនិច្ឆ័យជាសារវន្ត ដូចខាងក្រោម៖

- ការរកឃើញនិងការប្រមូលចំណូលបានពីប្រភពចំណូលថ្មី
- លទ្ធផលនៃការអនុវត្តចំណូលប្រចាំឆ្នាំសម្រេចបានលើសផែនការ
- ការប្រមូលចំណូលដែលស្ថិតនៅទីតាំងឆ្ងាយ ដាច់ស្រយាល និងស្ថានភាពលំបាកនៃគមនាគមន៍
- ការប្រមូលចំណូលធ្វើឡើងនៅថ្ងៃឈប់សម្រាកឬថ្ងៃបុណ្យជាតិ
- ការប្រមូលចំណូលដែលមានហានិភ័យដល់សុខភាពនិងសុវត្ថិភាពការងារ
- ការតឹងទារបំណុល ទទួលបានលទ្ធផលតាមរយៈការខិតខំប្រឹងប្រែងចាត់វិធានការ និងសកម្មអនុវត្តការតឹងទារបំណុល។

**មាត្រា៨៤ .-**

វិធាននិងនីតិវិធីនៃការពិនិត្យ ការវាយតម្លៃ និងផ្តល់ការលើកទឹកចិត្ត ត្រូវកំណត់ដោយអនុក្រឹត្យ។

## ផ្នែកទី២
## ការដាក់ទណ្ឌកម្ម

**មាត្រា៨៥ .-**

ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រមូលចំណូលមិនមែនសារពើពន្ធ ដែលមិនគោរព ឬមិនអនុវត្តតាមបញ្ញត្តិនៃច្បាប់នេះ និង/ឬលិខិតបទដ្ឋានគតិយុត្តជាធរមានពាក់ព័ន្ធនឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ អាចជាកម្មវត្ថុនៃការអនុវត្តវិធានការរឹតត្បិតផ្សេងៗ។

វិធាននិងនីតិវិធី នៃការអនុវត្តវិធានការរឹតត្បិត ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៨៦ .-**

អ្នករាជការសាធារណៈដែលត្រូវបានរកឃើញថាមិនគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះ និងលិខិតបទដ្ឋានគតិយុត្តជាធរមានដទៃទៀត ពាក់ព័ន្ធនឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ក្នុងការអនុវត្តមុខងារនិងភារកិច្ចរបស់ខ្លួន ត្រូវទទួលរងនូវទណ្ឌកម្មខាងវិន័យ ស្របតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមានដទៃទៀត ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌនិងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីដទៃទៀតឡើយ។

ក្នុងករណីដែលកំហុសរបស់អ្នករាជការសាធារណៈនោះ បានធ្វើឱ្យមានការបាត់បង់ប្រាក់កាសសាធារណៈ ឬចំណូលមិនមែនសារពើពន្ធ នោះតម្លៃនៃការបាត់បង់ឬការខូចខាត រួមទាំងការប្រាក់លើតម្លៃបាត់បង់ឬខូចខាតនេះ ក្លាយជាបំណុលរបស់អ្នករាជការសាធារណៈនោះ ដែលត្រូវសងនិងបង់ចូលថវិការដ្ឋវិញ។

**មាត្រា៨៧ .-**

រូបវន្តបុគ្គលឬនីតិបុគ្គលឯកជនដែលជាភាគីនៃលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ ជាមួយរដ្ឋទាំងឡាយណា ដែលមិនគោរពតាមលក្ខខណ្ឌដែលមានចែងក្នុងលិខិតគតិយុត្តត្រូវទទួលរងការពិន័យឬការចាត់វិធានការរដ្ឋបាល ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**មាត្រា៨៨ .-**

វិធាននៃការពិន័យនិងការដាក់ទណ្ឌកម្ម ដូចមានកំណត់នៅក្នុងច្បាប់នេះ ជាវិធានរួមនិងកម្រិតអប្បបរមា។

ក្នុងករណីដែលច្បាប់និងលិខិតបទដ្ឋានគតិយុត្តពិសេសដោយឡែក ព្រមទាំងលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ បានកំណត់អំពីការដាក់ពិន័យនិងការដាក់ទណ្ឌកម្ម ខ្ពស់ជាងវិធានកម្រិតអប្បបរមាដែលមានកំណត់នៅក្នុងច្បាប់នេះ ត្រូវអនុវត្តតាមវិធានពិសេសនិងដោយឡែកដែលមានចែងក្នុងច្បាប់ ឬលិខិតបទដ្ឋានគតិយុត្ត ឬលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធនោះ។

## ជំពូកទី១០

## ទោសប្បញ្ញត្តិ

**មាត្រា៨៩ .-**

បុគ្គលឯកជនដែលមិនទទួលបានសិទ្ធិពីរដ្ឋក្នុងការប្រមូលចំណូលមិនមែនសារពើពន្ធ ហើយធ្វើការប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ឆ្នាំ ទៅ ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី ៥០ ០០០ ០០០ (ហាសិបលាន)រៀល ទៅ ១០០ ០០០ ០០០ (មួយរយលាន)រៀល។

ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ និងពិន័យជាប្រាក់ទ្វេដង។

**មាត្រា៩០ .-**

បុគ្គលឯកជនទទួលបានសិទ្ធិពីរដ្ឋក្នុងការប្រមូលចំណូលមិនមែនសារពើពន្ធ ដែលទៅប្រមូលចំណូលផ្សេងទៀតដោយពុំបានអនុញ្ញាតដោយច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ឬលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ឆ្នាំ ទៅ ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី ៥០ ០០០ ០០០ (ហាសិបលាន)រៀល ទៅ ១០០ ០០០ ០០០ (មួយរយលាន)រៀល។

ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារនិងពិន័យជាប្រាក់ទ្វេដង។

**មាត្រា៩១ .-**

អ្នកតំណាង ឬអ្នកទទួលបញ្ជា ឬអ្នកទទួលសិទ្ធិបន្តពីបុគ្គលឯកជនទទួលបានសិទ្ធិពីរដ្ឋក្នុងការប្រមូលចំណូលមិនមែនសារពើពន្ធ ដែលទៅប្រមូលចំណូលផ្សេងទៀតដោយពុំបានអនុញ្ញាតដោយច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ឬលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ខែ ទៅ ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន)រៀល ទៅ ៤ ០០០ ០០០ (បួនលាន)រៀល។

ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ និងពិន័យជាប្រាក់ទ្វេដង។

**មាត្រា៩២ .-**

មន្ត្រីរាជការសាធារណៈឬពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ដែលប្រមូលប្រភេទចំណូលមិនមែនសារពើពន្ធ ដោយពុំបានអនុញ្ញាតដោយច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ឬលិខិតគតិយុត្តបង្កើត

ចំណូលមិនមែនសារពើពន្ធ ដូចមានចែងក្នុងចំណុចទី១នៃមាត្រា៥៩២(និយមន័យនៃវីតិក្រម)និងផ្តន្ទាទោសតាមមាត្រា៥៩៣(ទោសដែលត្រូវអនុវត្ត)នៃក្រមព្រហ្មទណ្ឌ។

ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារនិងពិន័យជាប្រាក់ទ្វេដង។

**មាត្រា៩៣ .-**

បុគ្គលទាំងឡាយណាដែលរារាំងដោយចេតនានាំឱ្យរាំងស្ទះឬខកខានដល់ការចុះត្រួតពិនិត្យឬការបំពេញភារកិច្ចប្រមូលចំណូលមិនមែនសារពើពន្ធរបស់អ្នករាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ឬបុគ្គលឯកជនដែលទទួលបានសិទ្ធិពីរដ្ឋក្នុងការប្រមូលចំណូលមិនមែនសារពើពន្ធ នៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ឆ្នាំ ទៅ៣ (បី)ឆ្នាំ និងពិន័យជាប្រាក់ពី ២ ០០០ ០០០(ពីរលាន)រៀល ទៅ ៦ ០០០ ០០០(ប្រាំមួយលាន)រៀល។

ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារនិងពិន័យជាប្រាក់ទ្វេដង។

**មាត្រា៩៤ .-**

បុគ្គលឯកជនទទួលបានសិទ្ធិពីរដ្ឋក្នុងការប្រមូលចំណូលមិនមែនសារពើពន្ធ ឬអ្នកតំណាង ឬអ្នកទទួលបញ្ជាដែលទាមទារលើស ឬលោះលា ឬលើកលែងនូវចំនួនប្រាក់នៃចំណូលមិនមែនសារពើពន្ធដែលត្រូវប្រមូល ដោយបានកំណត់ក្នុងច្បាប់ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ឬលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ឆ្នាំ ទៅ ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី ៤០ ០០០ ០០០ (សែសិបលាន)រៀល ទៅ ៨០ ០០០ ០០០ (ប៉ែតសិបលាន)រៀល។

ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារនិងពិន័យជាប្រាក់ទ្វេដង។

**មាត្រា៩៥ .-**

អ្នករាជការសាធារណៈឬពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោតដែលលោះលា ឬលើកលែងដោយខុសច្បាប់នូវចំនួនប្រាក់ឬប្រភេទចំណូលមិនមែនសារពើពន្ធដែលត្រូវប្រមូលដោយបានកំណត់ក្នុងច្បាប់ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ឬលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ)ឆ្នាំ ទៅ ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០(បួនលាន)រៀល ទៅ១០ ០០០ ០០០(ដប់លាន)រៀល។

ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារនិងពិន័យជាប្រាក់ទ្វេដង។

**មាត្រា៩៦ .-**

នីតិបុគ្គលអាចត្រូវបានប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌចំពោះបទល្មើសដែលមានចែងក្នុងមាត្រា៨៩ មាត្រា៩០ មាត្រា៩១ មាត្រា៩៣ និងមាត្រា៩៤ នៃច្បាប់នេះ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ទ្វេដង នៃចំនួនទឹកប្រាក់ពិន័យដែលមានចែងក្នុងមាត្រា៨៩ មាត្រា៩០ មាត្រា៩១ មាត្រា៩៣ និងមាត្រា៩៤ នៃច្បាប់នេះ ព្រមទាំងទោសបន្ថែមមួយ ឬច្រើនដូចមានចែងក្នុងមាត្រា១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ។

**មាត្រា៩៧ .-**

ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អ្នករាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ឬបុគ្គលឯកជនទទួលបានសិទ្ធិពីរដ្ឋក្នុងការប្រមូលចំណូលមិនមែនសារពើពន្ធ ឬអ្នកតំណាង ឬអ្នកទទួលបញ្ជា ឬបុគ្គលឯកជនមិនទទួលបានសិទ្ធិពីរដ្ឋក្នុងការប្រមូលចំណូលមិនមែនសារពើពន្ធ ចំពោះបទល្មើសដែលមានចែងក្នុងជំពូកទី១០

នៃច្បាប់នេះ ជាបទល្មើសពុករលួយដែលត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខតែមួយគត់របស់អង្គភាពប្រឆាំងអំពើពុករលួយ ក្នុងការស៊ើបអង្កេតនិងកសាងសំណុំរឿងពុករលួយទៅតុលាការ។

**មាត្រា៩៨ .-**

ការអនុវត្តបទប្បញ្ញត្តិនៃច្បាប់នេះ មិនរារាំងដល់ការអនុវត្តច្បាប់ព្រហ្មទណ្ឌដទៃទៀតទេ។

## ជំពូកទី១១

## អន្តរប្បញ្ញត្តិ

**មាត្រា៩៩ .-**

ក្នុងរយៈពេល ១(មួយ)ឆ្នាំ ក្រោយច្បាប់នេះចូលជាធរមាន លិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ ដែលបានធ្វើឡើងមុនច្បាប់នេះចូលជាធរមាន ដែលពុំទទួលបានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវធ្វើនីត្យានុកូលកម្មឡើងវិញ តាមវិធាននិងនីតិវិធីដែលកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្របតាមច្បាប់នេះ។ ក្នុងករណីចាំបាច់ រាជរដ្ឋាភិបាលអាចពន្យាររយៈពេលនៃការធ្វើនីត្យានុកូលកម្មនេះបន្ថែមទៀត។

**មាត្រា១០០ .-**

ច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធទាំងឡាយណា ដែលបានអនុវត្តមុនពេលច្បាប់នេះចូលជាធរមាន ត្រូវមានសុពលភាពអនុវត្តរហូតដល់មានច្បាប់ឬលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ដោយអនុលោមតាមច្បាប់នេះ។

## ជំពូកទី១២

## អវសានប្បញ្ញត្តិ

**មាត្រា១០១ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

ថ្ងៃ ព្រហស្បតិ៍ ៦រោច ខែ ផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ២០២២

ពរស.៤២០៥.៩៩៧

ន សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

# ឧបសម្ព័ន្ធនៃច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ

## សទ្ទានុក្រម

### ក

កម្រៃសួយសារឬថ្លៃសួយសារ សំដៅដល់ចំណូលដែលរូបវន្តបុគ្គល ឬនីតិបុគ្គលធ្វើអាជីវកម្ម ឬទាញយកធនធានធម្មជាតិ ត្រូវបង់ជូនរដ្ឋតាមបរិមាណផលិត ឬទាញយកបាន ក្រៅពីបុព្វលាភនិងមូលនិធិផ្សេងៗ។

ក្រសួង ស្ថាប័នដែលប្រមូលចំណូលមិនមែនសារពើពន្ធ ឬក្រសួង ស្ថាប័ន សំដៅដល់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ ក្រុមហ៊ុនចម្រុះដែលរដ្ឋមានភាគកម្មសាធារណៈជាចំនួនភាគតិច និងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត ដែលបំពេញមុខងារគ្រប់គ្រងនិងប្រមូលចំណូលមិនមែនសារពើពន្ធនៅថ្នាក់ជាតិ។

### គ

គណនេយ្យភាព សំដៅដល់ការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន ឬអង្គភាពសាធារណៈប្រហាក់ប្រហែល និងបុគ្គលចំពោះមុខងារ និងភារកិច្ចដែលបានទទួលអនុវត្តតាមប្រព័ន្ធរបាយការណ៍។

### ច

ចំណូលមិនមែនសារពើពន្ធ សំដៅដល់ចំណូលដែលទទួលបានមកពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ចំណូលពីសហគ្រាសសាធារណៈ ភាគកម្មសាធារណៈ និងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត ចំណូលពីសេវាសាធារណៈ ចំណូលពីការពិន័យនិងការដាក់ទណ្ឌកម្ម វៀរលែងតែការពិន័យនិងការដាក់ទណ្ឌកម្មពាក់ព័ន្ធនឹងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធផ្សេងទៀត។

ចំណូលដុល សំដៅដល់ចំណូលទាំងឡាយដែលមិនទាន់កាត់កងចំណាយណាមួយ នៅក្នុងសកម្មភាពអាជីវកម្ម ឬតាមការកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមានដទៃទៀត។

### ត

តម្លាភាព សំដៅដល់បរិយាកាសនៃការបើកទូលាយដល់ការចូលរួម ការតាមដាន ការពិនិត្យ និងការផ្តល់យោបល់គ្រប់ជ្រុងជ្រោយ ក៏ដូចជាការប្រកួតប្រជែងដោយសមធម៌ ដោយលក្ខណៈស្មើភាព និងយុត្តិធម៌។

### ទ

ទ្រព្យសម្បត្តិរដ្ឋ សំដៅដល់ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈដទៃទៀត ព្រមទាំងទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈដទៃទៀត។ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈដទៃទៀត អាចហៅនិងសរសេរក្នុងទម្រង់ខ្លីបានជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ។ ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈដទៃទៀត អាចហៅនិងសរសេរក្នុងទម្រង់ខ្លីបានជាទ្រព្យសម្បត្តិឯកជន

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

## ប

**បុគ្គលឯកជនទទួលបានសិទ្ធិពីរដ្ឋក្នុងការប្រមូលចំណូលមិនមែនសារពើពន្ធ** សំដៅដល់បុគ្គលឯកជនដែលទទួលបាននីតិសម្បទាពីរដ្ឋតាមរយៈលិខិតបទដ្ឋានគតិយុត្ត និង/ឬលិខិតគតិយុត្តិបង្កើតចំណូលមិនមែនសារពើពន្ធ ដើម្បីទៅប្រមូលចំណូលមិនមែនសារពើពន្ធ ឬបុគ្គលដែលទទួលបន្តនូវសិទ្ធិនិងកាតព្វកិច្ចមួយផ្នែកឬទាំងស្រុងដោយស្របច្បាប់ ដូចបានកំណត់ក្នុងច្បាប់ លិខិតបទដ្ឋានគតិយុត្ត និង/ឬលិខិតគតិយុត្តិបង្កើតចំណូលមិនមែនសារពើពន្ធ ពីបុគ្គលឯកជនដែលទទួលបាននីតិសម្បទាពីរដ្ឋ ដើម្បីទៅប្រមូលចំណូលមិនមែនសារពើពន្ធ។

**បុព្វលាភ** សំដៅដល់ចំណូលដែលអ្នកកាន់អាជ្ញាបណ្ណឬលិខិតអនុញ្ញាត ត្រូវបង់ជូនរដ្ឋតាមការកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន និងត្រូវបានរក្សាទុកសម្រាប់ប្រើប្រាស់ក្នុងគោលដៅរក្សានិរន្តរភាពបរិស្ថាន និងស្តារធម្មជាតិឡើងវិញ។

**ប្រសិទ្ធភាព** សំដៅដល់កម្រិតឬសមត្ថភាពដែលសម្រេចបានជាលទ្ធផលតាមការគ្រោងទុក ឬតាមគោលបំណងនៃការអភិវឌ្ឍសង្គមសេដ្ឋកិច្ច។

## ភ

**ភាគចំណែករបស់រដ្ឋ** សំដៅដល់ចំណូលរបស់រដ្ឋដែលបានមកពីការបែងចែកតាមអត្រាពីផលនៃការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ប្រតិបត្តិការអាជីវកម្មរវាងរដ្ឋនិងឯកជន ផលបានពីសម្បទានទ្រព្យសម្បត្តិរដ្ឋ និងផលដទៃទៀតតាមការកំណត់ក្នុងលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ ឬលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត។

**ភាគលាភ** សំដៅដល់ចំណែកទឹកប្រាក់ដែលបានពីការបែងចែកប្រាក់ចំណេញរបស់សហគ្រាសសាធារណៈ និងក្រុមហ៊ុនចម្រុះដែលរដ្ឋមានភាគកម្មសាធារណៈជាចំនួនភាគតិច ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ព្រមទាំងលក្ខន្តិកៈនៃការបង្កើតក្រុមហ៊ុន។

## ល

**លិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធឬលិខិតគតិយុត្ត** សំដៅដល់កិច្ចសន្យា កិច្ចព្រមព្រៀង សៀវភៅបន្ទុក អាជ្ញាបណ្ណ លិខិតអនុញ្ញាត និងលិខិតគតិយុត្តផ្សេងទៀត ដែលមានកម្មវត្ថុបង្កើតចំណូលមិនមែនសារពើពន្ធ ឬកំណត់អំពីកាតព្វកិច្ចហិរញ្ញវត្ថុសាធារណៈ។

**លិខិតបទដ្ឋានគតិយុត្ត** សំដៅដល់ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេចរាជរដ្ឋាភិបាល សារាចររាជរដ្ឋាភិបាល ប្រកាសក្រសួង ស្ថាប័ន សេចក្តីសម្រេចរបស់ក្រសួង ស្ថាប័ន និងសារាចររបស់ក្រសួង ស្ថាប័ន។

**លោះលា** សំដៅដល់អំពើបន្ធូរបន្ថយ។

## ស

**សកម្មងាយជាសាច់ប្រាក់** សំដៅដល់ទ្រព្យសកម្មដែលអាចបំប្លែងទៅជាសាច់ប្រាក់បានឆាប់រហ័ស។

**សង្គតិភាព** សំដៅដល់ ស្ថានភាពនៃការអនុវត្តគោលការណ៍តែមួយជាលក្ខណៈប្រទាក់ក្រឡាគ្នា រវាងក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ទាំងអស់របស់ព្រះរាជាណាចក្រកម្ពុជា។

**សក្តិសិទ្ធិភាព** សំដៅដល់ការប្រព្រឹត្តទៅ ឬការបំពេញការងារដែលសន្សំសំចៃចំណាយពេលតិច។ ការប្រព្រឹត្តទៅឬការបំពេញការងារដែលខិតខំប្រឹងប្រែងតិចតួច តែទទួលបានលទ្ធផលគាប់ប្រសើរ។

**សេវាសាធារណៈ** សំដៅដល់រាល់សកម្មភាពទាំងឡាយ ដែលធ្វើឡើងដោយស្ថាប័នរដ្ឋ ឬភ្នាក់ងាររដ្ឋ ឬអាជ្ញាធរគ្រប់លំដាប់ថ្នាក់ទាំងអស់របស់រដ្ឋ ដែលបំពេញការងារតាមដែនសមត្ថកិច្ចរបស់ខ្លួន ឬធ្វើឡើងដោយផ្នែកឯកជន ឬសង្គមស៊ីវិលដែលទទួលបានសិទ្ធិនិងភារកិច្ចពីរដ្ឋ ដែលស្ថិតនៅក្រោមការគ្រប់គ្រងត្រួតពិនិត្យរបស់រដ្ឋ ឬភ្នាក់ងាររដ្ឋក្នុងគោលដៅបម្រើផលប្រយោជន៍សាធារណៈ។

**ស្ថាប័ននិម្មាបនករ** សំដៅដល់ស្ថាប័នដែលមានសិទ្ធិនិងអំណាចក្នុងការផ្តួចផ្តើម ដឹកនាំ រៀបចំ និងគ្រប់គ្រង។

**សម្បទានសេវាសាធារណៈ** សំដៅដល់ការប្រគល់សិទ្ធិរបស់រដ្ឋ ទៅឱ្យបុគ្គលឯកជនក្នុងការផ្គត់ផ្គង់សេវាសាធារណៈដោយផ្ទាល់ឬដោយប្រយោល ដើម្បីជាប្រយោជន៍សាធារណៈ តាមរយៈការសាងសង់គម្រោងហេដ្ឋារចនាសម្ព័ន្ធនានា ឬតាមរយៈការផ្តល់សិទ្ធិជូនបុគ្គលឯកជនលើការធ្វើអាជីវកម្មលើទ្រព្យសម្បត្តិរដ្ឋ ឬលើសេវាសាធារណៈដែលពុំមែនជាសេវាអធិបតេយ្យរបស់រដ្ឋ។ សម្បទានសេវាសាធារណៈ ចែកចេញជាគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន និងសម្បទានគ្រប់គ្រងសេវាសាធារណៈ។

ឣ

**អង្គភាពស្វ័យភាពហិរញ្ញវត្ថុ** សំដៅដល់អង្គភាពស្វ័យភាពហិរញ្ញវត្ថុនៃនីតិបុគ្គលសាធារណៈ ដែលធ្វើអាជីវកម្មសេវាកម្ម មានលក្ខណៈពាណិជ្ជកម្ម និងមិនស្ថិតក្រោមទម្រង់នៃសហគ្រាសសាធារណៈ ឬគ្រឹះស្ថានសាធារណៈរដ្ឋបាលដោយសារទំហំអាជីវកម្ម សេវាកម្ម ឬកម្រិតដើមទុន ឬលក្ខណៈពិសេសនៃកិច្ចប្រតិបត្តិការរបស់ខ្លួន។

**អតិរេកសាច់ប្រាក់** សំដៅដល់ខ្ទង់ចំណូលដែលនៅសល់ជាក់ស្តែង ក្រោយពេលដែលចំណូលគ្រប់ប្រភេទដែលទទួលបាន ដកចេញនូវចំណាយគ្រប់ប្រភេទដែលបានចំណាយរួច។

**អសាធនភាព** សំដៅដល់ភាពមិនអាចសងបំណុលទាំងអស់បាន តាមឥណប្រតិទាន។

**អ្នកទទួលសិទ្ធិបន្តពីបុគ្គលឯកជនទទួលបានសិទ្ធិពីរដ្ឋក្នុងការប្រមូលចំណូលមិនមែនសារពើពន្ធ** សំដៅដល់បុគ្គលដែលទទួលបន្តនូវសិទ្ធិនិងកាតព្វកិច្ចមួយផ្នែកឬទាំងស្រុង ពីបុគ្គលឯកជនទទួលបានសិទ្ធិពីរដ្ឋក្នុងការប្រមូលចំណូលមិនមែនសារពើពន្ធដោយពុំបានបំពេញនីតិវិធីជាធរមាន ដូចបានកំណត់ក្នុងច្បាប់ លិខិតបទដ្ឋានគតិយុត្ត និង/ឬលិខិតគតិយុត្តិបង្កើតចំណូលមិនមែនសារពើពន្ធ។

ឥ

**ឥណប្រតិទាន** សំដៅដល់កាលបរិច្ឆេទតម្រូវឱ្យបង់ប្រាក់។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL